ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្ទឹងត្រែង
លេខ.....០៩៤/១៦ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តស្ទឹងត្រែង ជំរុញចលនាភូមិ១ផលិតផល១

## អភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៩ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវ នៃក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៥៣ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ-បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងសេចក្តីសម្រេចលេខ ០៨៩/១៦ សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តស្ទឹងត្រែង ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការខេត្តស្ទឹងត្រែង ជំរុញចលនាភូមិ១ផលិតផល១

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តស្ទឹងត្រែង ជំរុញចលនាភូមិ១ផលិតផល១ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- លោក | **ផាន់ យុត** | នាយករងរដ្ឋបាលសាលាខេត្ត | ប្រធាន |
| ២- លោក | **ណាយ សុភិរម្យ** | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣- លោក | **ព្រាំ ពេជ្រ** | អនុប្រធានមន្ទីរអភិវឌ្ឍជនបទខេត្ត | អនុប្រធាន |
| ៤- លោក | **អៀង គន្ធា** | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | អនុប្រធាន |
| ៥-លោក | **លី មីណា** | អភិបាលរងក្រុងស្ទឹងត្រែង | សមាជិក |
| ៦-លោក | **សុវណ្ណ ពិសេដ្ឋ** | អភិបាលរងស្រុកសេសាន | សមាជិក |
| ៧-លោក | **ស្ងួន ចាន់រដ្ឋា** | អភិបាលរងស្រុកសៀមបូក | សមាជិក |
| ៨-លោក | **សរ សុផល** | អភិបាលរងស្រុកសៀមប៉ាង | សមាជិក |
| ៩-លោក | **អ៊ុក ចាន់ថន** | អភិបាលរងស្រុកថាឡាបរិវ៉ាត់ | សមាជិក |
| ១០-លោក | **ភឿ ស៊ីថាត** | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត | សមាជិក |
| ១១- លោកស្រី | **ប៉ាន បញ្ញារ៉ា** | អនុប្រធានមន្ទីរកិច្ចការនារីខេត្ត | សមាជិក |
| ១២-លោក | **មាន សុខធឿន** | អនុប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ១៣-លោក | **ម៉ែន រិទ្ធិ** | អនុប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ១៤-លោក | **ឃឿម លីនណា** | អនុប្រធានមន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | សមាជិក |
| ១៥-លោកស្រី | **ញោច សារឿន** | អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | សមាជិក |
| ១៦-លោកស្រី | **ពេជ ស៊ីធឿន** | អនុប្រធានមន្ទីរព័ត៌មានខេត្ត | សមាជិក |
| ១៧-លោក | **អ៊ូច សុផល** | នាយករងទីចាត់ការអន្តរវិស័យ | សមាជិក។ |

**ប្រការ ២._**

លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តស្ទឹងត្រែងជំរុញចលនាភូមិ១ផលិតផល១ មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

- ត្រូវប្រជុំរៀងរាល់០៣ខែម្តង ក្នុងករណីពិសេសណាមួយ កិច្ចប្រជុំត្រូវធ្វើឡើងស្ថិតក្រោមអធិបតីភាពប្រធាន ឬអនុប្រធានទទួលសិទ្ធិ នៃគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ផលិតផល១
- រៀបចំកិច្ចប្រជុំ របស់គណៈកម្មាធិការខេត្ត ជំរុញចលនាភូមិ១ផលិតផល១
- រៀបចំគ្រោងផែនការសកម្មភាព និងថវិកា តាមបណ្តាឆ្នាំនីមួយៗ
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- បំពេញកិច្ចការផ្សេងៗទៀត តាមការណែនាំរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ផលិតផល១

**ប្រការ ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤._**

នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការ និងប្រធានអង្គភាពចំណុះសាលាខេត្ត រដ្ឋបាលក្រុង ស្រុក ប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅខេត្តស្ទឹងត្រែង, ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០១៦

**អភិបាល**

ទ៊ុំ សារឿន

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ១-៤
- ឯកសារ-កាលប្បវត្តិ



អាសយដ្ឋាន : ភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
Address : Trapeang Pring Village, Sangkat Stung Treng, Stung Treng City, Stung Treng Province
លេខទូរស័ព្ទ/ទូរសារ (Tel/Fax): +855 (0)74 210 407 / +855 (0)74 210 410
អ៊ីមែល (E-mail): stungtreng@stg.ncdd.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តស្ទឹងត្រែង**
គណៈកម្មាធិការខេត្តជំរុញចលនា ភ១ផ១
លេខ៖ ០១/១៦ ភផក

# របាយការណ៍
## ស្តីពី
## សកម្មភាពការងារប្រចាំខែតុលា ឆ្នាំ២០១៦
* * * * * *

### ១. ស្ថានភាពទូរទៅ៖

រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រុមប្រឹក្សាស្តារកសិកម្ម និងអភិវឌ្ឍន៍ បានយកចិតទុកដាក់ ក្នុងការជំរុញសហគមន៍មូលដ្ឋាន គ្រឹស្ថានសិប្បកម្មនានា ក្នុងការជំរុញចលនាភូមិ១ផលិតផល១ ឆ្លុះបញ្ចាំងពីលក្ខណៈវប្បធម៌ប្រពៃណីតាមបែបបុរាណនិងតាមបែបសម័យទំនើប ដែលផ្តល់នូវកិត្យានុភាព និងមោទនភាពចំពោះភូមិឋានខ្លួនកំពុងរស់នៅ ហើយផលិតផលទាំងនេះមានសក្តានុពលអាចពង្រឹង និងពង្រីកបានទាំងបរិមាណ គុណភាព និងសោភ័ណ្ឌភាព ដើម្បីជួយបង្កើននូវប្រាក់ចំណូល លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។

### ២. សក្តានុពលរបស់ខេត្ត ៖

ខេត្តស្ទឹងត្រែង មានដងទន្លេ ចំនួន ០៤ហូរកាត់ មានទន្លេមេគង្គ ទន្លេសេកុង ទន្លេសេសាន និងទន្លេស្រែពក ។ មានផ្ទៃដីទូលំទូលាយ  សម្រាប់បង្កបង្កើនផល ដូចជាស្រូវ ក្រូច ស្វាយចន្ទី ម្នាស់ ពោត ចេក សណ្តែក កៅស៊ូ ដូងប្រេង និងដំណាំរួមផ្សំដទៃទៀត។ ខេត្ត មានផ្ទៃដីទូលាយសម្រាប់ចិញ្ចឹមសត្វ ដូចជាគោ ក្របី ជាដើម។ ជាមួយគ្នានេះផងដែរ ខេត្ត មានតំបន់រម្មណីយ៍ដ្ឋានជាច្រើនកន្លែង ដែលជាសក្តានុពលអាចជួយជំរុញចលនាភូមិ១ផលិតផល១ ឱ្យមានការរីកចម្រើនទៅថ្ងៃអនាគត។

**ក.ផលិតផល៖** ស្រាដំណើបស និងខ្មៅ មាននៅក្នុងឃុំព្រះរំកិល ស្រុកថាឡាបរីវ៉ាត់ ទំនាក់ទំនងតាមទូរស័ព្ទលេខ ០១១ ៩១៦ ២២៥។

**ខ.ផលិតផល៖** អង្ករ៉ាមសា មាននៅក្នុងឃុំអន្លង់ជ្រៃ ស្រុកថាឡាបរីវ៉ាត់ ទំនាក់ទំនងតាម ទូរស័ព្ទលេខ ០១៧ ៨៤២ ៥៩១។

**គ.ផលិតផល៖** ចង្កឹះទ្រាំង មាននៅក្នុងឃុំអន្លង់ជ្រៃ ស្រុកថាឡាបរីវ៉ាត់ ទំនាក់ទំនងតាម ទូរស័ព្ទលេខ ០១៧ ៨៤២ ៥៩១។

**ឃ.ផលិតផល៖** ម្ទាស់ទឹកឃ្មុំ មាននៅក្នុងឃុំអូរប្រឡង់ ស្រុកសៀមបូក ទំនាក់ទំនងតាមទូរស័ព្ទ លេខ ០៩៧ ៤៧ ៧៨ ៨៦៤។

**ង.ផលិតផល៖** ក្រឡាន មាននៅក្នុងសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ។

**ច.ផលិតផល៖** ណែម មាននៅក្នុងសង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង

## ៣. លទ្ធផលសម្រេចបានក្នុងខែ៖

| **កូដ** | **សកម្មភាពអាទិភាព** | % **សម្រេចបាន** | **ខែ** | | | | | |
|---|---|---|---|---|---|---|---|---|
| | | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| 1.2 | រៀបចំកិច្ចប្រជុំសម្របសម្រួលរៀងរាល់ខែ ឬ៣ខែម្តង នៅក្នុងគណៈកម្មាធិការថ្នាក់ខេត្ត | ១០០% | | | √ | | | |
| 1.4 | កែសម្រួល សមាសភាពគណៈកម្មាធិការ | ១០០% | | | √ | | | |
| 1.5 | បង្កើតលេខាធិការដ្ឋាន ភ១ ផ១ របស់គណៈកម្មាធិការខេត្ត | ១០០% | | | | √ | | |
| 3.1 | ស្រាវជ្រាវ និង ចងក្រងប្រភេទផលិតផលសក្តានុពលនានាក្នុងខេត្ត | ៥០% | | | √ | √ | | |

## ៤. បញ្ហាប្រឈម៖

| **ល.រ** | **បញ្ហាប្រឈម** | **សំណើដំណោះស្រាយ** |
|---|---|---|
| ១ | គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ផលិតផល១ មិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ | សំណូមពរ ក្រុមប្រឹក្សាស្តារកសិកម្ម និងអភិវឌ្ឍន៍ ជួយបណ្តុះបណ្តាល |
| ២ | ផលិតករ មានការខ្វះខាតថវិកា និងបច្ចេកទេស | សំណូមពរជួយបណ្តុះបណ្តាលបច្ចេកទេស |
| ៣ | ការផ្សព្វផ្សាយព័ត៌មាន និងពាណិជ្ជកម្ម មិនទាន់បានទូលំទូលាយ | ខិតខំផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ និងតាមបណ្តាញសង្គម |
| ៤ | ផលិតផលបានហើយ នៅខ្វះទីផ្សារលក់ដូរ | |

## ៥. ទិសដៅអនុវត្តន៍បន្ត ៖

| កូដ | សកម្មភាពអាទិភាព | ខែ | | | | | |
|---|---|---|---|---|---|---|---|
| | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| 3.2 | ស្រាវជ្រាវពីតម្រូវការពង្រឹងគុណភាព ឬបច្ចេកទេសសនានាជូនសមាគម សហគមន៍ សហគ្រាស | | | | | | |
| 4.1 | រៀបចំផែនការផ្សព្វផ្សាយឲ្យបានទូលំទូលាយពីគោលគំនិតចលនាភូមិ១ផលិតផល១ តាមកិច្ចប្រជុំនានានៅតាមសហគមន៍ សាលារៀន វត្តអារ៉ាម, វិទ្យុ FM , ទូរទស្សន៍, ទស្សនាវត្តី..... | | | | | | |

## ៦. សេចក្តីសន្និដ្ឋាន៖

គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ផលិតផល១ បានខិតខំជំរុញសកម្មភាពផលិតផលិតផលដើម្បីបំពេញតម្រូវការផ្គត់ផ្គង់ទីផ្សារក្នុងខេត្ត និងសម្រាប់បំរើឲ្យភ្ញៀវទេសចរណ៍ ដែលមកទស្សនានៅក្នុងខេត្ត។ ប៉ុន្តែដោយសារតែដំណើរការផលិតកម្មរបស់ប្រជាពលរដ្ឋ ផលិតបានកាន់តែច្រើន គឺមិនសូវមានទីផ្សារ ខ្វះថវិកាទិញវត្ថុធាតុដើម លក់បានតម្លៃទាបមិនសមស្របជាមួយតម្លៃផលិត ដោយសារវត្ថុធាតុដើមមានតម្លៃថ្លៃ មធ្យោបាយបាយដឹកជញ្ជូនឆ្ងាយទៅកាន់ទីផ្សារ និងម្យ៉ាងវិញទៀតនៅខ្វះព័ត៌មានចេញទៅរកទីផ្សារខាងក្រៅ។

ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ផលិតផល១ នឹងខិតខំបន្ថែមទៀត ជំរុញចលនានេះឱ្យកាន់តែមានសកម្មភាព កៀគរដៃគូរដើម្បីជួយដល់ការវិនិយោគ និងខិតខំស្វែងរកទីផ្សារខាងក្រៅ ព្រមទាំងចងក្រងបង្កើតសមាគមន៍តាមលទ្ធភាពជាក់ស្តែង ដើម្បីគាំទ្រ និងទ្រទ្រង់ដល់ផលិតករ ឱ្យមានស្នេហភាពក្នុងការធ្វើអាជីវកម្មនៅតាមមូលដ្ឋាននានាក្នុងខេត្ត។

ធ្វើនៅខេត្តស្ទឹងត្រែង.,ថ្ងៃទី២៥ ខែត្រូវ....ឆ្នាំ២០១៦

**អភិបាល**

**ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ផលិតផល១**

ម៉ុម សារឿន